# មេរៀនទី ១៣៦: សាឡូម៉ូនសរសេរសុភាសិតជាច្រើន

## ១ ពង្សាវតារក្សត្រ ៤:២៩-៤៣ និង សុភាសិត ១:១-១៧

| | |
|---|---|
| **គោលបំណង៖** | ព្រះអង្គគឺជាប្រភពនៃប្រាជ្ញា។ |

**ខគម្ពីរចងចាំ៖ សុភាសិត ៣:១៣** *"សប្បាយហើយ អស់អ្នកណាដែលរកបានប្រាជ្ញា ហើយអ្នកណាដែលខំប្រឹងទាល់តែបានយោបល់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ប្រាជ្ញាគឺជាការយល់ពីអ្វីដែលព្រះសព្វព្រះទ័យសម្រាប់យើង។ នៅពេលដែលយើងរីកចម្រើននៃសមត្ថភាពក្នុងការស្តាប់ និងគោរពតាមប្រាជ្ញារបស់ព្រះគ្រីស្ទ នោះព្រះយេស៊ូវបានចម្រើនយើងឡើងវិញ ហើយជួយយើងរស់នៅសម្រាប់ទ្រង់។ សូមអាន **សុភាសិត ១:៧**។ កន្លែងចាប់ផ្តើមនៃប្រាជ្ញា គឺការមានការគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះ។ តើអ្នកបង្ហាញការគោរពចំពោះព្រះដោយរបៀបណា? សូមពិនិត្យមើលកាលវិភាគរបស់អ្នក។ តើមានពេលវេលា និងផ្នែកណាខ្លះក្នុងជីវិតរបស់អ្នក ដែលជាពេលដ៏ពិបាកក្នុងការបង្ហាញការគោរពចំពោះព្រះ? ចំណុចលំបាកទាំងនេះគឺជាឱកាសសម្រាប់ប្រាជ្ញារបស់ព្រះ ដើម្បីបំភ្លឺនៅក្នុងជីវិតរបស់អ្នក។

**ចំរៀង៖** ១.បើអ្នកសប្បាយក្នុងព្រះយេស៊ូវ ២.ខ្ញុំសប្បាយរីករាយ ៣.ព្រះយេស៊ូវជាព្រះអម្ចាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «ល្បែងផែនដីក្រឡាប់ចាក់ »

**សម្ភារ:ដែលត្រូវការ៖** ក្រដាសកាតុង ដែលមានម្ខាងពណ៌ក្រហម និងផ្នែកម្ខាងទៀតពណ៌ស (ទាំងអស់ឲ្យបាន ៣០សន្លឹក)



១. ចែកកុមារជាពីរក្រុម

២. ដែលក្រុមទី ១ ជាក្រុមក្រហម ហើយក្រុមទី២ ជាក្រុមស

៣. គ្រូត្រូវដាក់ក្រដាសកាតុងទាំងអស់នោះនៅលើឥដ្ឋចម្រុះពណ៌គ្នា

៤. កុមារមានពេល ៣នាទីក្នុងការបង្វែរពណ៌កាតុងនោះឲ្យទៅជាពណ៌ក្រុមរបស់ពួកគេ

៥. ក្រុមណាដែលអាចប្តូរពណ៌ក្រដាសកាតុង ទៅជាពណ៌ក្រុមរបស់ខ្លួនបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា យើងត្រូវការប្រាជ្ញាដែលបានមកពីព្រះ ដើម្បីប្តូរក្រដាសកាតុងនោះទៅជាពណ៌ក្រុមរបស់ខ្លួនហើយការពារវា។ នៅក្នុងជីវិតរស់នៅរបស់យើង យើងតែងតែត្រូវការប្រាជ្ញាដើម្បីដោះស្រាយបញ្ហាហើយព្រះគឺជាប្រភពនៃប្រាជ្ញា។

**៤. ការណែនាំមេរៀន**

តើប្អូនគិតថា នរណាដែលឆ្លាតជាងគេនៅក្នុងថ្នាក់របស់យើងនេះ? តើមានប្អូនៗប៉ុន្មាននាក់ធ្លាប់រៀនជាប់លេខមួយខ្លះ? តើមានប្អូនៗណាខ្លះធ្លាប់រៀនជាប់លេខ២? ចុះលេខ៣? លេខ៤? លេខ៥? ព្រះបានប្រទាន

អំណោយទានជាច្រើនដល់យើងមានដូចជា រៀនពូកែ អ្នកខ្លះពូកែច្រៀង ពូកែរាំ ពូកែញញឹម ពូកែនិយាយ ពូកែធ្វើអាហារ នោះគឺអំណោយទាននៃប្រាជ្ញា ដែលមានន័យថាដឹងនូវអ្វីដែលត្រឹមត្រូវគួរធ្វើ។ ព្រះគម្ពីរបានរំលឹកពីពាក្យនៃប្រាជ្ញាច្រើនជាង៣០០ដង។ ហើយវាក៏ស្ទើរតែដូចនឹងពាក្យមួយដែលព្រះគម្ពីរបានរំលឹក ជាពាក្យដែលពិពណ៌នាពីព្រះបានយ៉ាងល្អគឺក្តីស្រឡាញ់។ ថ្ងៃនេះយើងនឹងរៀនពីសាឡូម៉ូន ជាអ្នកដែលបានប្រើប្រាជ្ញាដែលព្រះបានប្រទានឲ្យគាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរប្រាប់យើងថាប្រាជ្ញាដែលព្រះបានប្រទានឲ្យសាឡូម៉ូន គឺដូចជាខ្សាច់ដែលមាននៅលើមាត់សមុទ្រក្នុងលោកីយ៍នេះ។ សាឡូម៉ូនដឹងថាមានអ្វីៗជាច្រើនដែលគ្មាននរណាអាចរាប់បាន ឬគ្មានអ្នកអាចវាស់បាននោះគឺប្រាជ្ញាដែលព្រះបានប្រទានឲ្យសាឡូម៉ូន។ ប្រាជ្ញារបស់សាឡូម៉ូគឺបន្តកើនឡើងជាបន្តបន្ទាប់ មនុស្សគ្រប់គ្នានៅជុំវិញពិភពលោកនេះដឹងថាសាឡូម៉ូនជាអ្នកដែលមានប្រាជ្ញាជាងគេលើលោក។

គាត់បានបង្រៀនមនុស្សអំពីដើមឈើ និងសត្វ។ គាត់បានពន្យល់អំពីអាថ៌កំបាំងដែលគ្មានអ្នកណាអាចយល់បាន។ គាត់បានបង្ហាញណែនាំពីរបៀបដែលធ្វើឲ្យគេក្លាយជាមនុស្សល្អប្រសើរជាងមុន។ គាត់បានបង្ហាញពិភពលោកថាព្រះអស្ចារ្យប៉ុណ្ណា ហើយមនុស្សតូចតាចប៉ុណ្ណា? គាត់បានបង្រៀនមនុស្សគ្រប់គ្នាថា យើងមិនអាចរស់ដោយគ្មានព្រះនោះទេ។ គាត់បានចែករំលែកប្រាជ្ញាដែលព្រះប្រទានមកឲ្យគាត់ ទៅមនុស្សគ្រប់គ្នានៅទូទាំងផែនដីនេះ។ តាមពិតទៅប្រាជ្ញារបស់សាឡូម៉ូនពិតជាអស្ចារ្យណាស់ ដែលនៅតែអាចបង្រៀនដល់យើងសព្វថ្ងៃនេះ។

ប្រាជ្ញាមានន័យថា ការដឹងពីអ្វីត្រឹមត្រូវដែលត្រូវធ្វើហើយធ្វើអ្វីៗដោយប្រាជ្ញា ដែលនេះជាផ្លូវដ៏ល្អដែលយើងត្រូវធ្វើ។ សាឡូម៉ូនបានសរសេរសៀវភៅនៅក្នុងព្រះគម្ពីរ ដើម្បីជួយយើងគ្រប់គ្នាឲ្យយល់ថា តើប្រាជ្ញាមានសារៈសំខាន់យ៉ាងណាចំពោះព្រះ។ សៀវភៅនោះឈ្មោះថា **សុភាសិត**។ គ្រប់ខគម្ពីរទាំងអស់នៅក្នុង សុភាសិតប្រាប់មនុស្សពីប្រាជ្ញានៅក្នុងការរស់នៅ។ ហើយខគម្ពីរសុភាសិតប្រាប់យើងជាញឹកញាប់ពីរបៀបរស់នៅដោយប្រាជ្ញា និងរបៀបរស់នៅដោយគ្មានប្រាជ្ញា គឺដើម្បីជួយយើងឲ្យយល់ពីផ្លូវនៃប្រាជ្ញា។

ជាឧទាហរណ៍ ការស្តាប់ពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយជារឿងដ៏ឈ្លាសវៃដែលត្រូវធ្វើ។ វានឹងមិនសមហេតុផលទេក្នុងការមិនស្តាប់បង្គាប់ឪពុកម្តាយរបស់អ្នក។ ការទុកចិត្តព្រះនិងធ្វើតាមការណែនាំរបស់ព្រះ គឺជារឿងដ៏ឈ្លាសវៃដែលត្រូវធ្វើ។ វាមិនសមហេតុផលទេក្នុងការបដិសេធព្រះ ហើយអ្នកមិនឆ្លាតទេដែលធ្វើអ្វីៗតាមវិធីផ្ទាល់ខ្លួនរបស់អ្នកនោះ។

ព្រះទ្រង់ប្រទានប្រាជ្ញាដល់យើង ដូចជាទ្រង់ប្រទានប្រាជ្ញាដល់សាឡូម៉ូនដែរ។ តើយើងអាចរកឃើញប្រាជ្ញារបស់ព្រះនៅឯណា? យើងអាចរកឃើញប្រាជ្ញាពីការស្គាល់ព្រះ និងមាគ៌ារបស់ព្រះតាមរយៈព្រះគម្ពីរ និងតាមរយៈការថ្វាយបង្គំ! ចូរយើងទាំងអស់គ្នាមានប្រាជ្ញា និងដឹងថាអ្វីដែលត្រូវធ្វើ!

## ៦. សំនួរពិភាក្សា

១. តើនរណាជាអ្នកមានប្រាជ្ញាបំផុតមកដល់សព្វថ្ងៃនេះ? *ស្តេចសាឡូម៉ូន*

២. តើសៀវភៅណាក្នុងគម្ពីរដែលនិយាយពីប្រាជ្ញារបស់ស្តេចសាឡូម៉ូន? *សុភាសិត*

៣. តើប្រាជ្ញាជាអ្វី? *ដឹងពីអ្វីត្រឹមត្រូវដែលត្រូវធ្វើ*

៤. តើអ្នកអាចស្វែងរកប្រាជ្ញានៅឯណា?

*ដោយការស្គាល់ព្រះ និងមាគ៌ារបស់ព្រះ តាមរយៈព្រះគម្ពីរ និងការថ្វាយបង្គំ*

## ៧. **ល្បែងកំសាន្ត** «ឆ្លាត? ឬមិនឆ្លាត?»



១. ចែកកុមារជាពីរក្រុម ឬច្រើនក្រុម។

២. ជ្រើសរើសតំណាងសម្រាប់ក្រុមនីមួយៗ។

៣. គ្រូនឹងប្រាប់ក្មេងៗដែលបានជ្រើសរើសនូវរឿងមួយ។ ប្រសិនបើកុមារគិតថា មនុស្សក្នុងរឿងនោះមានប្រាជ្ញា ពួកគេគួរតែលោតចុះ ឡើង ដោយនិយាយថា “ឆ្លាត”។ ប្រសិនបើកុមារគិតថា មនុស្សនៅក្នុងរឿងនោះមិនឆ្លាត ពួកគេគួរតែរមៀលលើដីខណៈពេលដែលនិយាយថា “មិនឆ្លាត”)



៤. អ្នកតំណាងដែលឆ្លើយបានមុនគេដោយលោតឡើងចុះឬរមៀលលើដី នោះក្រុមពួកគេនឹងទទួលបានពិន្ទុ។

៥. គ្រូគួររៀបចំរឿងខ្លះដូចឧទាហរណ៍ខាងក្រោម។

ក. ដាវីឌបានជឿទុកចិត្តលើព្រះ ហើយគាត់មិនមានការភ័យខ្លាចក្នុងការប្រយុទ្ធជាមួយកុលីយ៉ាតនោះទេ។ (លោតឡើងចុះហើយនិយាយថា “ឆ្លាត”)

ខ. កាអ៊ីនបានសម្លាប់អេប៊ិលដោយសារការច្រណែន។(រមៀលលើដីហើយនិយាយថា“មិនឆ្លាត”)

គ. ឧត្តមបានស្តាប់បង្គាប់ម្តាយ ហើយលាងដៃមុនពេលបរិភោគ។ (លោតឡើងចុះក្រោមហើយនិយាយថា “ឆ្លាត”)

ឃ. កញ្ញាបានធ្វើឲ្យរបស់លេងមិត្តភក្តិនាងខូច ហើយនាងមិនបានប្រាប់គាត់ថាខូចទេ។ (រមៀលលើដីហើយនិយាយថា “មិនឆ្លាត”)

## ៨. **ខគម្ពីរចងចាំ** *សុភាសិត ៣:១៣*

## ៩. **ហត្ថកម្ម** «ទន្សាយឆ្លាត»



**សម្ភារៈដែលត្រូវការ៖** ព្រីនរូបទន្សាយ ការបិត កន្ត្រៃ

១. ឲ្យក្រដាសរូបទន្សាយដល់កុមារម្នាក់មួយៗ។

២. ឱ្យកុមារតុបតែងទន្សាយ ដោយគូរមុខរបស់វានិងផាត់ពណ៌វា។

៣. ឱ្យកុមារសរសេរខគម្ពីរចងចាំនៅលើទន្សាយនោះ។

៤. បន្ទាប់ពីធ្វើរួច សូមពន្យល់កុមារថា ទន្សាយដ៏ឈ្លាសវៃប្រាប់យើងថា សុភាសិត ៣:១៣“សប្បាយហើយអស់អ្នកណាដែលរកបានប្រាជ្ញា ហើយអ្នកណាដែលខំប្រឹងទាល់តែបានយោបល់”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ*

# ទន្សាយឆ្លាត

